# دُعَاءُ كُمَيْل

اللَّهُمَّ إِنِّيْ أَسْأَلُكَ بِرَحْمَتِكَ الَّتِيْ وَسِعَتْ كُلَّ شَيْءٍ،
អល់ឡោះហ៍អឺយ ទូលព្រះបង្គំជាខ្ញុំបួងសួងព្រះអង្គ អាស្រ័យព្រះមេត្តាធម៌ព្រះអង្គ ដែលគ្របដណ្ដប់លើសព្វសារពើ

وَ بِقُوَّتِكَ الَّتِيْ قَهَرْبَ بِها كُلَّ شَيْءٍ، وَ خَضَعَ لَها كُلُّ شَيْءٍ وَ ذَلَّ لَهَا كُلُّ شَيْءٍ،
អាស្រ័យព្រះរាជកម្លាំងពលំព្រះអង្គ ព្រះអង្គគ្រប់គ្រងសព្វសារពើ សព្វសារពើចុះចូលក្រោមព្រះរាជកម្លាំងពលំព្រះអង្គ សព្វសារពើដាក់ខ្លួនចំពោះព្រះរាជកម្លាំងពលំព្រះអង្គ

وَ بِجَبَرُوْتِكَ الَّتِيْ غَلَبْتَ بِهَا كُلُّ شَيْءٍ، وَ بِعِزَّتِكَ الَّتِيْ لَا يَقُوْمُ لَهَا شَيْءٌ،
អាស្រ័យព្រះអបរាជ័យព្រះអង្គ ព្រះអង្គមានជ័យជំនះលើសព្វសារពើ អាស្រ័យព្រះព្រះមហិទ្ធិឫទ្ធិព្រះអង្គពុំមានអ្វីអាចស៊ូព្រះអង្គបានឡើយ

وَ بِعَظَمَتِكَ الَّتِيْ مَلَأَتْ كُلَّ شَيْءٍ، وَ بِسُلْطَانِكَ الَّذِيْ عَلَا كُلَّ شَيْءٍ،
អាស្រ័យព្រះវិសាលភាពរបស់ព្រះអង្គ ដែលពោរពេញក្នុងព្វសារពើ អាស្រ័យព្រះតេជានុភាពព្រះអង្គដែលខ្ពង់ខ្ពស់លើសសព្វសារពើ

وَ بِوَجْهِكَ الْبَاقِيْ بَعْدَ فَنَاءِ كُلِّ شَيْءٍ، وَ بِأَسْمَائِكَ الَّتِيْ مَلَأَتْ أَرْكَانَ كُلِّ شَيْءٍ،
អាស្រ័យព្រះភក្ត្រព្រះអង្គដែលគង់នៅជានិច្ចនិរន្តរ ក្រោយពីសព្វសារពើបានវិនាសសូន្យបង់ អាស្រ័យព្រះនាមទាំងឡាយរបស់ព្រះអង្គដែលពោរពេញក្នុងគ្រឹះនៃសព្វសារពើ

وَ بِعِلْمِكَ الَّذِيْ أَحَاطَ بِكُلِّ شَيْءٍ، وَ بِنُوْرِ وَجْهِكَ الَّذِيْ أَضَاءَ لَهُ كُلُّ شَيْءٍ،

ដោយនូវព្រះអភិញ្ញាព្រះអង្គដែលគ្របដណ្តប់សព្វសារពើ ដោយនូវព្រះរស្មីនៃព្រះភក្ត្រព្រះអង្គដែលបំភ្លឺសព្វសារពើ

يَا نُوْرُ يَا قُدُّوْسُ، يَا أَوَّلَ الْأَوَّلِيْنَ، وَ يَا آخِرَ الْآخِرِيْنَ.

ឱព្រះរស្មី ឱព្រះសន្ត, ឱព្រះដំបូងបង្អស់នៃបណ្តាសព្វសារពើដំបូងបង្អស់ ឱព្រះចុងក្រោយបង្អស់នៃបណ្តាសព្វសាពើចុងក្រោយបង្អស់

اللَّهُمَّ اغْفِرْ لِيَ الذُّنُوْبَ الَّتِيْ تَهْتِكُ الْعِصَمَ،

អល់ឡោះហ្ញ៍អឺយ សូមទ្រង់ព្រះមេត្តាអភ័យទោសឲ្យទូលព្រះបង្គំជាខ្ញុំដែលបានសាងបាបដែលបន្ថោកព្រហ្មចរិយភាព

اللَّهُمَّ اغْفِرْ لِيَ الذُّنُوْبَ الَّتِيْ تُنْزِلُ النِّقَمَ،

អល់ឡោះហ្ញ៍អឺយ សូមទ្រង់ព្រះមេត្តាអភ័យទោសឲ្យទូលព្រះបង្គំជាខ្ញុំដែលបានសាងបាបដែលនាំមកនូវទណ្ឌកម្ម

اللَّهُمَّ اغْفِرْ لِيَ الذُّنُوْبَ الَّتِيْ تُغَيِّرُ النِّعَمَ،

អល់ឡោះហ្ញ៍អឺយ សូមទ្រង់ព្រះមេត្តាអភ័យទោសឲ្យទូលព្រះបង្គំជាខ្ញុំដែលបានសាងបាបដែលបង្ខូចសេចក្តីល្អ

اللَّهُمَّ اغْفِرْ لِيَ الذُّنُوْبَ الَّتِيْ تَحْبِسُ الدُّعَاءَ،

អល់ឡោះហ្ញ៍អឺយ សូមទ្រង់ព្រះមេត្តាអភ័យទោសឲ្យទូលព្រះបង្គំជាខ្ញុំដែលបានសាងបាបដែលរាំងរាការអង្វរបួងសួង

اللَّهُمَّ اغْفِرْ لِيَ الذُّنُوْبَ الَّتِيْ تُنْزِلُ الْبَلَاءَ،

អល់ឡោះហ្ញ៍អឺយ សូមទ្រង់ព្រះមេត្តាអភ័យទោសឲ្យទូលព្រះបង្គំជាខ្ញុំដែលបាន

សាងបាបដែលនាំមកនូវគ្រោះកំណាច

اللَّهُمَّ اغْفِرْ لِيَ كُلَّ ذَنْبٍ أَذْنَبْتُهُ، وَ كُلَّ خَطِيْئَةٍ أَخْطَأْتُهَا،
អល់ឡោះហ៊្ញអឺយ សូមទ្រង់ព្រះមេត្តាអភ័យទោសឲ្យទូលព្រះបង្គំជាខ្ញុំផងដែលបានសាងបាប ដែលបានប្រព្រឹត្តកំហុស

اللَّهُمَّ إِنِّيْ أَتَقَرَّبُ إِلَيْكَ بِذِكْرِكَ، وَاسْتَشْفِعُ بِكَ إِلَى نَفْسِكَ،
អល់ឡោះហ៊្ញអឺយ ទូលព្រះបង្គំជាខ្ញុំខិតចូលទៅជិតព្រះអង្គដោយការរលឹកដល់ព្រះអង្គ ទូលព្រះបង្គំជាខ្ញុំសូមធ្វើអន្តរាគមន៍ចំពោះព្រះអង្គឲ្យខ្លួនទូលព្រះបង្គំជាខ្ញុំ

وَ أَسْأَلُكَ بِجُوْدِكَ أَنْ تُدْنِيَنِيْ مِنْ قُرْبِكَ، وَ أَنْ تُوْزِعَنِيْ شُكْرَكَ، وَ أَنْ تُلْهِمَنِيْ ذِكْرَكَ .
ទូលព្រះបង្គំជាខ្ញុំអង្វរសូមព្រះអង្គ ក្នុងព្រះនាមនៃព្រះហប្ញទ័យទូលំទូលាយរបស់ព្រះអង្គ ឲ្យទូលព្រះបង្គំជាខ្ញុំបានចូលជិតព្រះអង្គ ឲ្យព្រះអង្គជួយរំលឹកទូលព្រះបង្គំជាខ្ញុំឲ្យទូលព្រះបង្គំជាខ្ញុំអរព្រះគុណព្រះអង្គ និងសូមឲ្យព្រះអង្គជួយរំលឹកទូលព្រះបង្គំជាខ្ញុំឲ្យរលឹកដល់ព្រះអង្គ

اللَّهُمَّ إِنِّيْ أَسْأَلُكَ سُؤَالَ خَاضِعٍ مُتَذَلِّلٍ خَاشِعٍ، أَنْ تُسَامِحَنِيْ وَ تَرْحَمَنِيْ،
អល់ឡោះហ៊្ញអឺយ ទូលព្រះបង្គំជាខ្ញុំអង្វរបួងសួងព្រះអង្គ ដោយចុះចូលទាំងកាយទាំងចិត្តចំពោះព្រះអង្គ ដោយដាក់ខ្លួន សុំព្រះអង្គព្រះមេត្តាអភ័យទោសនិងមានព្រះមេត្តាប្រណីដល់ទូលព្រះបង្គំជាខ្ញុំផង

وَ تَجْعَلَنِيْ بِقَسْمِكَ رَاضِيًا قَانِعًا، وَ فِيْ جَمِيْعِ الْأَحْوَالِ مُتَوَاضِعًا .
សូមទ្រង់ព្រះមេត្តាឲ្យទូលព្រះបង្គំជាខ្ញុំត្រេកអរ និងពេញចិត្តចំពោះអ្វីដែលព្រះអង្គបានព្រះរាជទានឲ្យមកទូលព្រះបង្គំជាខ្ញុំ និងឲ្យទូលព្រះបង្គំជាខ្ញុំដាក់ខ្លួនរាបសាគ្រប់ប្រការ

اللَّهُمَّ وَ أَسْأَلُكَ سُؤَالَ مَنْ اشْتَدَّتْ فَاقَتُهُ ، وَ أَنْزَلَ بِكَ عِنْدَ الشَّدَائِدِ حَاجَتَهُ ، وَ عَظُمَ فِيْمَا عِنْدَكَ رَغْبَتُهُ ،

អល់ឡោះហ៍អឺយ ទូលព្រះបង្គំជាខ្ញុំអង្វរសុំព្រះអង្គក្នុងនាមនៃបុគ្គលម្នាក់ដែលកាន់តែក្រខ្សត់ជាដរាប ដែលបួងសួងព្រះអង្គក្នុងគ្រាមានគ្រោះកាច ដែលប្រាថ្នាខ្លាំងជាទីបំផុតនូវអ្វីដែលនៅឯព្រះអង្គ

اللَّهُمَّ عَظُمَ سُلْطَانُكَ وَ عَلَا مَكَانُكَ ، وَ خَفِيَ مَكْرُكَ وَ ظَهَرَ أَمْرُكَ ، وَ غَلَبَ قَهْرُكَ وَ جَرَتْ قُدْرَتُكَ ، وَ لَا يُمْكِنُ الْفِرَارُ مِنْ حُكُوْمَتِكَ ،

អល់ឡោះហ៍អឺយ អំណាចព្រះអង្គវិសេសវិសាលបំផុត ព្រះរាជស្ថានទីរបស់ព្រះអង្គខ្ពង់ខ្ពស់បំផុត ល្បិចព្រះអង្គលាក់បាំងបំផុត ព្រះអាជ្ញាធរព្រះអង្គជាក់ស្តែង ព្រះឥទ្ធិពលព្រះអង្គសម្បើមក្រៃលែង ព្រះមហិទ្ធិឫទ្ធិព្រះអង្គមាននៅសព្វអន្លើ ពុំអាចគេចផុតពីការគ្រប់គ្រងរបស់ព្រះអង្គបានឡើយ

اللَّهُمَّ لَا أَجِدُ لِذُنُوْبِيْ غَافِرًا وَ لَا لِقَبَائِحِيْ سَاتِرًا ، وَ لَا لِشَيْءٍ مِنْ عَمَلِيْ الْقَبِيْحَ بِالْحَسَنِ مُبَدِّلًا غَيْرَكَ ،

អល់ឡោះហ៍អឺយ ទូលព្រះបង្គំជាខ្ញុំមិនឃើញមានអ្នកណាក្រៅពីព្រះអង្គទេដែលអាចលើកលែងបាបទូលព្រះបង្គំជាខ្ញុំ ដែលអាចបិទបាំងអំពើថោកទាបរបស់ទូលព្រះបង្គំជាខ្ញុំ ដែលអាចប្តូរអំពើអាក្រក់របស់ទូលព្រះបង្គំជាខ្ញុំទៅជាអំពើល្អវិញ

لَا إِلَهَ إِلَّا أَنْتَ سُبْحَانَكَ وَ بِحَمْدِكَ

ពុំមានព្រះទេក្រៅពីព្រះអង្គ សូមថ្វាយសេចក្តីរុងរឿងនិងសេចក្តីសរសើរចំពោះព្រះអង្គ

ظَلَمْتُ نَفْسِيْ، وَ تَجَرَّأْتُ بِجَهْلِيْ، وَ سَكَنْتُ إِلَى قَدِيْمِ ذِكْرِكَ لِيْ وَ مَنِّكَ عَلَيَّ،
ទូលព្រះបង្គំជាខ្ញុំបានប្រព្រឹត្តខុសលើខ្លួនឯង ទូលព្រះបង្គំជាខ្ញុំចចេស[ប្រព្រឹត្តខុស]ព្រោះតែទូលព្រះបង្គំជាខ្ញុំល្ងង់ខ្លៅ ទូលព្រះបង្គំជាខ្ញុំពឹងផ្អែកទៅលើព្រះកម្រើននិងព្រះមេត្តាករុណារបស់ព្រះអង្គ ដែលព្រះអង្គមានមកលើរូបទូលព្រះបង្គំជាខ្ញុំជានិច្ច

اللَّهُمَّ مَوْلَايَ كَمْ مِنْ قَبِيْحٍ سَتَرْتَهُ، وَ كَمْ مِنْ فَادِحٍ مِنَ الْبَلَاءِ أَقَلْتَهُ،
អល់ឡោះហ៍អើយ ព្រះអគ្គប្រមុខទូលព្រះបង្គំជាខ្ញុំអើយ ព្រះអង្គបានបិទបាំងអំពើអប្រិយដ៏ច្រើនរបស់ទូលព្រះបង្គំជាខ្ញុំ ព្រះអង្គបានឲ្យទូលព្រះបង្គំជាខ្ញុំចៀសផុតពីភ័យវិបត្តិភ័យដ៏ច្រើន

وَ كَمْ مِنْ عِثَارٍ وَقَيْتَهُ ، وَ كَمْ مِنْ مَكْرُوْهٍ دَفَعْتَهُ، وَ كَمْ مِنْ ثَنَاءٍ جَمِيْلٍ لَسْتُ أَهْلًا لَهُ نَشَرْتَهُ،
ព្រះអង្គបានការពារទូលព្រះបង្គំជាខ្ញុំឲ្យផុតពីការភ្លាំងភ្លាត់ដ៏ច្រើន ព្រះអង្គបានរុញច្រានគ្រោះកាចដ៏ច្រើនឆ្ងាយពីទូលព្រះបង្គំជាខ្ញុំ ព្រះអង្គបានប្រោះរោយមកលើរូបទូលព្រះបង្គំជាខ្ញុំ នូវសេចក្ដីសរសើរដ៏ប្រណិតដ៏ច្រើនដែលទូលព្រះបង្គំជាខ្ញុំពុំសមនឹងបានឡើយ

اللَّهُمَّ عَظُمَ بَلَائِيْ وَ أَفْرَطَ بِيْ سُوْءُ حَالِيْ، وَ قَصُرَتْ بِيْ أَعْمَالِيْ ،
អល់ឡោះហ៍អើយ ទុក្ខរបស់ទូលព្រះបង្គំជាខ្ញុំកាន់តែខ្លាំងឡើង ស្ថានភាពទូលព្រះបង្គំជាខ្ញុំដុនដាបពន់ពេក អំពើល្អរបស់ទូលព្រះបង្គំជាខ្ញុំក៏ខ្វះ

وَ قَعَدَتْ بِيْ أَغْلَالِيْ، وَ حَبَسَنِيْ عَنْ نَفْعِيْ بُعْدُ آمَالِيْ
ច្រវ៉ាក់[នៃបាប]ទូលព្រះបង្គំជាខ្ញុំចងទូលព្រះបង្គំជាខ្ញុំជាប់ សេចក្ដីសង្ឃឹមហួសហេតុរបស់ទូលព្រះបង្គំជាខ្ញុំ មិនផ្ដល់ផលប្រយោជន៍ណាមួយដល់ទូលព្រះបង្គំជា

ខ្ញុំឡើយ

وَ خَدَعَتْنِيْ الدُّنْيَا بِغُرُوْرِهَا، وَ نَفْسِيْ بِخِيَانَتِهَا ، وَ مِطَالِيْ يا سَيِّدِيْ
លោកនេះបានបោកបញ្ឆោតទូលព្រះបង្គំជាខ្ញុំដោយភាពឥតខ្លឹមសាររបស់វា [និងបោកបញ្ឆោត]ព្រលឹងទូលព្រះបង្គំជាខ្ញុំដោយសេចក្តីវៀចវេររបស់វា និងដោយការរារែករបស់ទូលព្រះបង្គំជាខ្ញុំ ឱម្ចាស់ទូលព្រះបង្គំជាខ្ញុំអើយ

فَأَسْأَلُكَ بِعِزَّتِكَ أَنْ لَا يَحْجُبَ عَنْكَ دُعَائِيْ سُوْءُ عَمَلِيْ وَ فِعَالِيْ ،

ដូច្នេះ ទូលព្រះបង្គំជាខ្ញុំសូមព្រះអង្គ ក្នុងព្រះនាមព្រះមហិទ្ធិឫទ្ធិព្រះអង្គ កុំឲ្យបណ្តាអំពើអាក្រក់របស់ទូលព្រះបង្គំជាខ្ញុំជារបាំងរវាងអង្វរបួងសួងរបស់ទូលព្រះបង្គំជាខ្ញុំ និងព្រះអង្គឡើយ

وَ لَا تَفْضَحَنِيْ بِخَفِيِّ مَا اطَّلَعْتَ عَلَيْهِ مِنْ سِرِّيْ،
សូមទ្រង់ព្រះមេត្តាកុំបើកឲ្យគេឃើញឡើយ នូវរឿងកំបាំងនានារបស់ទូលព្រះបង្គំជាខ្ញុំដែលព្រះអង្គទ្រង់ញាណ

وَ لَا تُعَاجِلْنِيْ بِالْعُقُوْبَةِ عَلَى مَا عَمِلْتُهُ فِيْ خَلَوَاتِيْ مِنْ سُوْءِ فِعْلِيْ وَ إِسَاءَتِيْ،
សូមទ្រង់ព្រះមេត្តាកុំប្រញាប់ធ្វើទោសទូលព្រះបង្គំជាខ្ញុំ ដោយសារតែទូលព្រះបង្គំជាខ្ញុំបានធ្វើអាក្រក់ និងដោយសារតែទូលព្រះបង្គំជាខ្ញុំបានសាងកំហុសក្នុងពេលធ្វេសប្រហែសខ្លួន

وَ دَوَامِ تَفْرِيْطِيْ وَ جَهَالَتِيْ ، وَ كَثْرَةِ شَهَوَاتِيْ وَ غَفْلَتِيْ،
[ដោយសារតែ]ការប្រព្រឹត្តខុសគន្លង និងសេចក្តីល្ងង់ខ្លៅជានិច្ចរបស់ទូលព្រះបង្គំជាខ្ញុំ [ដោយសារតែ]តណ្ហាហួសហេតុនិងការធ្វេសប្រហែសរបស់ទូលព្រះបង្គំជាខ្ញុំ

وَ كُنْ اللّهُمَّ بِعِزَّتِكَ لِيْ فِيْ الْأَحْوَالِ كُلِّهَا رَؤُوْفًا، وَ عَلَيَّ فِيْ جَمِيْعِ الْأُمُوْرِ عَطُوْفًا،
អល់ឡោះហ៊ូអឺយ ក្នុងព្រះនាមនៃព្រះមហិទ្ធិឫទ្ធិព្រះអង្គ សូមទ្រង់ព្រះមេត្តាប្រណី ដល់ទូលព្រះបង្គំជាខ្ញុំគ្រប់កាលៈទេសៈ សូមទ្រង់ព្រះសន្ដោសចំពោះគ្រប់កិច្ចការ របស់ទូលព្រះបង្គំជាខ្ញុំ

إِلَهِيْ وَ رَبِّيْ مَنْ لِي غَيْرُكَ أَسْأَلُهُ كَشْفَ ضُرِّيْ والنَّظَرَ فِيْ أَمْرِيْ،
ឱព្រះទូលព្រះបង្គំជាខ្ញុំអឺយ ឱព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំអឺយ ឲ្យទូលព្រះបង្គំជាខ្ញុំ អង្វរបួងសួងអ្នកណាក្រៅពីព្រះអង្គ ដើម្បីនឹងសូមឲ្យជួយសម្រាលទុក្ខ និងសូម មេត្តាគិតគូរអំពីស្ថានភាពទូលព្រះបង្គំជាខ្ញុំ ?

إِلَهِيْ وَ مَوْلَايَ أَجْرَيْتَ عَلَيَّ حُكْمًا اتَّبَعْتُ فِيْهِ هَوَى نَفْسِيْ وَلَمْ أَحْتَرِسْ فِيْهِ مِنْ تَزْيِيْنِ عَدُوِّيْ،
ឱព្រះទូលព្រះបង្គំជាខ្ញុំអឺយ ឱព្រះរាជអគ្គមហាប្រមុខទូលព្រះបង្គំជាខ្ញុំអឺយ ព្រះ អង្គបានដាក់បញ្ជាមកលើទូលព្រះបង្គំជាខ្ញុំ តែទូលព្រះបង្គំជាខ្ញុំបានធ្វើតាមតែ អារម្មណ៍ឯង មិនបានប្រុងប្រយ័តចំពោះការទាក់ទាញចិត្តរបស់សត្រូវទូលព្រះបង្គំ ជាខ្ញុំឡើយ

فَغَرَّنِيْ بِمَا أَهْوَى وَأَسْعَدَهُ عَلَى ذَلِكَ الْقَضَاءُ
ដូច្នេះ វាបានបោកបញ្ឆោតទូលព្រះបង្គំជាខ្ញុំដោយអ្វីដែលទូលព្រះបង្គំជាខ្ញុំចង់បាន ដោយផ្អែកទៅលើជោគវាសនា

فَتَجَاوَزْتُ بِمَا جَرَى عَلَيَّ مِنْ ذَلِكَ بَعْضَ حُدُوْدِكَ، وَخَالَفْتُ بَعْضَ أَوَامِرِكَ،
ដូច្នេះវាបណ្ដាលឲ្យទូលព្រះបង្គំជាខ្ញុំល្មើសច្បាប់របស់ព្រះអង្គមួយផ្នែក ដែលព្រះ អង្គបានដាក់មកលើទូលព្រះបង្គំជាខ្ញុំក្នុងស្ថានភាពនេះ ហើយទូលព្រះបង្គំជាខ្ញុំ

បានល្មើសព្រះបណ្តាំមួយចំនួនរបស់ព្រះអង្គ

فَلَكَ الْحُجَّةُ عَلَيَّ فِيْ جَمِيْعِ ذَلِكَ، وَ لَا حُجَّةَ لِيْ فِيْمَا جَرَى عَلَيَّ فِيْهِ قَضَاؤُكَ، وَأَلْزَمَنِيْ حُكْمُكَ وَبَلَآؤُكَ،

សូមថ្វាយសេចក្តីសរសើរចំពោះព្រះអង្គ ដែលបានកាត់ក្តីទូលព្រះបង្គំជាខ្ញុំរឿងនេះ ព្រោះទូលព្រះបង្គំជាខ្ញុំពុំមានពាក្យតវ៉ាឡើយទល់ព្រះបញ្ញត្តិរបស់ព្រះអង្គ ទល់ការសម្រេចសេចក្តីរបស់ព្រះអង្គ និងទល់ទោសដែលព្រះអង្គដាក់មកលើទូលព្រះបង្គំជាខ្ញុំ

وَ قَدْ أَتَيْتُكَ يَا إِلَهِيْ بَعْدَ تَقْصِيْرِيْ وَإِسْرَافِيْ عَلَى نَفْسِيْ

ទូលព្រះបង្គំជាខ្ញុំប្រឡប់មករកព្រះអង្គវិញ ឱព្រះទូលព្រះបង្គំជាខ្ញុំអើយ ក្រោយពីមានផលវិបត្តិ និងបានប្រព្រឹត្តខុសគន្លង

مُعْتَذِرًا نَادِمًا مُنْكَسِرًا مُّسْتَقِيْلًا مُسْتَغْفِرًا مُنِيْبًا مُقِرًّا مُذْعِنًا مُعْتَرِفًا،

ទូលព្រះបង្គំជាខ្ញុំត្រឡប់មករកព្រះអង្គវិញ ឱព្រះទូលព្រះបង្គំជាខ្ញុំអើយ បន្ទាប់ពីបានប្រព្រឹត្តខុសនិងបានសាងបាប ដើម្បីសូមខមាទោសចំពោះព្រះអង្គ ដោយស្តាយក្រោយ ដោយខូចទឹកចិត្ត ដោយអង្វរសូមលើកលែងទោស ដោយអង្វរសូមស្មារលាកំហុស ភ្ជាក់រលឹកមិនប្រព្រឹត្តខុសទៀត ដោយសូមទទួលស្គាល់បាប[របស់ទូលព្រះបង្គំជាខ្ញុំ] មិនរឹងរូស សារភាពទោស[ចំពោះព្រះអង្គ]

لَا أَجِدُ مَفَرًّا مِمَّا كَانَ مِنِّيْ وَ لَا مَفْزَعًا أَتَوَجَّهُ إِلَيْهِ فِيْ أَمْرِيْ، غَيْرَ قَبُوْلِكَ عُذْرِيْ، وَإِدْخَالِكَ إِيَّايَ فِيْ سَعَةٍ مِنْ رَحْمَتِكَ،

ទូលព្រះបង្គំជាខ្ញុំពុំអាចគេចផុតពីអំពើដែលទូលព្រះបង្គំជាខ្ញុំបានធ្វើនោះទេ ហើយពុំមានកន្លែងណាមួយដែលទូលព្រះបង្គំជាខ្ញុំទៅជ្រកបានទេ ក្រៅពីព្រះអង្គព្រមទទួលនូវការសូមខមាទោសរបស់ទូលព្រះបង្គំជាខ្ញុំ និងការព្រមទទួលទូលព្រះបង្គំ

ជាខ្ញុំឲ្យបាននៅក្រោមព្រះមេត្តាករុណាដ៏ធំធេងរបស់ព្រះអង្គ

اللَّهُمَّ فَاقْبَلْ عُذْرِي وَارْحَمْ شِدَّةَ ضُرِّي، وَفُكَّنِي مِنْ شَدِّ وَثَاقِي،

ដូច្នេះ ឱអល់ឡោះហ៊្វអឺយ សូមទ្រង់ព្រះមេត្តាទទួលការសុំទោសរបស់ទូលព្រះបង្គំជាខ្ញុំ សូមទ្រង់ព្រះមេត្តាអាណិតអាសូរទូលព្រះបង្គំជាខ្ញុំដែលទទួលរងការខូចខាតជាទម្ងន់ សូមព្រះមេត្តាដោះទូលព្រះបង្គំជាខ្ញុំឲ្យរួចពីច្រវ៉ាក់ដ៏ធ្ងន់ផង

يَارَبِّ ارْحَمْ ضَعْفَ بَدَنِي وَرِقَّةَ جِلْدِي وَ دِقَّةَ عَظْمِي،

ឱព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំអឺយ សូមទ្រង់ព្រះមេត្តាអាណិតអាសូរដល់រូបកាយដ៏អន់ខ្សោយរបស់ទូលព្រះបង្គំជាខ្ញុំ ដល់ស្បែកដ៏ស្តើងរបស់ទូលព្រះបង្គំជាខ្ញុំ ដល់ឆ្អឹងដ៏ផ្ទាររបស់ទូលព្រះបង្គំជាខ្ញុំផង

يَا مَنْ بَدَأَ خَلْقِي وَذِكْرِي وَتَرْبِيَتِي وَبِرِّي وَتَغْذِيَتِي، هَبْنِي لِابْتِدَاءِ كَرَمِكَ وَسَالِفِ بِرِّكَ بِي،

ឱព្រះដែលដើមហេតុនៃការកកើតទូលព្រះបង្គំជាខ្ញុំ នៃឈ្មោះទូលព្រះបង្គំជាខ្ញុំ នៃការអប់រំទូលព្រះបង្គំជាខ្ញុំ នៃសុខុមាលភាពទូលព្រះបង្គំជាខ្ញុំ នៃចំណីទូលព្រះបង្គំជាខ្ញុំ សូមទ្រង់ព្រះមេត្តាបន្តការផ្តត់ផ្គង់ដល់ទូលព្រះបង្គំជាខ្ញុំតទៅទៀត ក្នុងព្រះនាមនៃព្រះមេត្តាករុណានិងព្រះគុណូបការៈ ដែលព្រះអង្គបានប្រទានមកលើទូលព្រះបង្គំជាខ្ញុំកាលពីមុនមកហើយនោះផង

يَا إِلَهِي وَسَيِّدِي وَرَبِّي، أَتُرَاكَ مُعَذِّبِي بِنَارِكَ بَعْدَ تَوْحِيدِكَ،

ឱព្រះទូលព្រះបង្គំជាខ្ញុំអឺយ ឱព្រះអភិបាលទូលព្រះបង្គំជាខ្ញុំអឺយ ឱព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំអឺយ ព្រះអង្គនឹងឲ្យទូលព្រះបង្គំជាខ្ញុំទទួលទោសភ្លើងនរកបន្ទាប់ពីទូលព្រះបង្គំជាខ្ញុំបានប្តេជ្ញាចិត្តថាព្រះអង្គជាព្រះតែមួយគត់

وَبَعْدَ مَا انْطَوَى عَلَيْهِ قَلْبِي مِنْ مَعْرِفَتِكَ، وَلَهِجَ بِهِ لِسَانِي مِنْ ذِكْرِكَ، وَاعْتَقَدَهُ

ضَمِيْرِيْ مِنْ حُبِّكَ،

[បន្ទាប់ពី]បេះដូងទូលព្រះបង្គំជាខ្ញុំពោរពេញដោយព្រះអភិញ្ញាព្រះអង្គ អណ្តាតទូលព្រះបង្គំជាខ្ញុំរវល់តែបួងសួងព្រះអង្គ អារម្មណ៍ទូលព្រះបង្គំជាខ្ញុំជឿយ៉ាងមាំលើសេចក្តីស្រឡាញ់ព្រះអង្គ

وَبَعْدَ صِدْقِ اعْتِرَافِيْ وَدُعَائِيْ خَاضِعًا لِرُبُوْبِيَّتِكَ،

[បន្ទាប់ពី]ទូលព្រះបង្គំជាខ្ញុំបានសារភាពកំហុសយ៉ាងស្មោះ និងបានបួងសួងព្រះអង្គដោយដាក់កាយថ្វាយចិត្តក្រោមព្រះបារមីព្រះអង្គឬ ?

هَيْهَاتَ أَنْتَ أَكْرَمُ مِنْ أَنْ تُضَيِّعَ مَنْ رَبَّيْتَهُ، أَوْ تُبْعِدَ مَنْ أَدْنَيْتَهُ،

មិនដូច្នេះជាដាច់ខាត ! ព្រះអង្គមានព្រះហឫទ័យទូលំទូលាយពេកណាស់ ព្រះអង្គមិនបោះបង់ចោលបុគ្គលដែលព្រះអង្គបានលើកតម្កើង មិនច្រានចោលបុគ្គលដែលព្រះអង្គបានឲ្យចូលមកជិតហើយនោះទេ

أَوْ تُشَرِّدَ مَنْ آوَيْتَهُ، أَوْ تُسَلِّمَ إِلَى الْبَلَاءِ مَنْ كَفَيْتَهُ وَ رَحِمْتَهُ،

មិនបណ្តេញចោលបុគ្គលដែលព្រះអង្គបានឲ្យជម្រកអាស្រ័យ មិនទុកជនណាម្នាក់ដែលព្រះអង្គបានជួយសង្គ្រោះនិងមេត្តាប្រណីឲ្យរងក្នុងទុក្ខវេទនាឡើយ !

وَ لَيْتَ شِعْرِيْ يَا سَيِّدِيْ وَ إِلَهِيْ وَ مَوْلَايَ،

ឱព្រះអភិបាលទូលព្រះបង្គំជាខ្ញុំអើយ ឱព្រះទូលព្រះបង្គំជាខ្ញុំអើយ ឱព្រះអគ្គប្រមុខទូលព្រះបង្គំជាខ្ញុំអើយ

أَتُسَلِّطُ النَّارَ عَلَى وُجُوْهٍ خَرَّتْ لِعَظَمَتِكَ سَاجِدَةً، وَ عَلَى أَلْسُنٍ نَطَقَتْ بِتَوْحِيْدِكَ صَادِقَةً، وَبِشُكْرِكَ مَادِحَةً،

តើព្រះអង្គអាចដុតភ្លើងនរកកើតឬ ទៅលើបណ្តាមុខដែលបានក្រាបប្រណិប័តន៍វិសាលភាពរបស់ព្រះអង្គ ទៅលើបណ្តាអណ្តាតដែលបានប្តេជ្ញាព្រមទទួលព្រះអង្គជាព្រះតែមួយគត់ដោយស្មោះស្ម័គ្រ ហើយអរព្រះគុណព្រះអង្គដោយពោលសរសើរព្រះអង្គ

وَ عَلَى قُلُوْبٍ اعْتَرَفَتْ بِإِلَهِيَّتِكَ مُحَقِّقَةً، وَ عَلَى ضَمَائِرَ حَوَتْ مِنَ الْعِلْمِ بِكَ حَتَّى صَارَتْ خَاشِعَةً،

ទៅលើបណ្តាបេះដូងដែលបានទទួលស្គាល់ព្រះអង្គជាព្រះដោយជឿជាក់ ទៅលើបណ្តាដួងវិញ្ញាណដែលជោកជាំដោយព្រះអភិញ្ញាព្រះអង្គ ដរាបធ្វើឲ្យពួកគេដាក់ខ្លួន

وَ عَلَى جَوَارِحَ سَعَتْ إِلَى أَوْطَانِ تَعَبُّدِكَ طَائِعَةً، وَأَشَارَتْ بِاسْتِغْفَارِكَ مُذْعِنَةً،

ទៅលើបណ្តាអវយវៈដែលបានទៅកាន់បណ្តាបូជនីយដ្ឋានរបស់ព្រះអង្គ ដើម្បីបញ្ជាក់នូវភក្តីភាពចំពោះព្រះអង្គ និងដើម្បីសូមខមាទោសព្រះអង្គដោយដាក់កាយថ្វាយចិត្ត ?

مَا هَكَذَا الظَّنُّ بِكَ وَ لَا أُخْبِرْنَا بِفَضْلِكَ عَنْكَ يَا كَرِيْمُ،

ទេ ! អស់ទូលព្រះបង្គំជាខ្ញុំមិនជឿថាព្រះអង្គដូចនេះទេ ចំណែកឯព្រះមេត្តាធម៌របស់ព្រះអង្គដែលអស់ទូលព្រះបង្គំជាខ្ញុំបានដឹងនោះក៏ដូច្នេះដែរ ឱព្រះដ៏មានព្រះហឫទ័យទូលាយលើសលុបអើយ

يَا رَبِّ وَأَنْتَ تَعْلَمُ ضَعْفِي عَنْ قَلِيْلٍ مِنْ بَلَاءِ الدُّنْيَا وَعُقُوْبَاتِهَا، وَ مَا يَجْرِيْ فِيْهَا مِنَ الْمَكَارِهِ عَلَى أَهْلِهَا،

ឱព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំអឺយ ព្រះអង្គទ្រង់ញាណច្បាស់ថាទូលព្រះបង្គំជាខ្ញុំទន់ខ្សោយពេកណាស់នៅចំពោះទុក្ខវេទនានិងទារុណកម្មបន្តិចបន្តួចនៃលោកនេះ និងនៅចំពោះបណ្តាគ្រោះកាចដែលកើតមានដល់ប្រជាពលរាស្ត្រនៃលោកនេះ

عَلَى أَنَّ ذَٰلِكَ بَلَاءٌ وَمَكْرُوْهٌ، قَلِيْلٌ مَكْثُهُ، يَسِيْرٌ بَقَاؤُهُ، قَصِيْرٌ مُدَّتُهُ،

ទោះបីវាជាទុក្ខវេទនានិងជាគ្រោះកាចដែលមិនឋិតថេរ ដែលឆាប់ផុត ដែលមិនយូរក៏ដោយ

فَكَيْفَ احْتِمَالِيْ لِبَلَاءِ الْآخِرَةِ وَجَلِيْلِ وُقُوْعِ الْمَكَارِهِ فِيْهَا،

ដូច្នេះ តើទូលព្រះបង្គំជាខ្ញុំនឹងអាចស៊ូទ្រាំបានដូចម្តេចទៅ ការរងទុក្ខវេនានៃលោកមុខ គ្រោះកាចដ៏សាហាវដែលកើតមាននៅទីនោះ

وَ هُوَ بَلَآءٌ تَطُوْلُ مُدَّتُهُ، وَيَدُوْمُ مَقَامُهُ، وَ لَا يُخَفَّفُ عَنْ أَهْلِهِ،

ដែលជាទុក្ខវេទនាដ៏យូរ ជានិច្ចនិរន្តរ ដែលមិនត្រូវបន្ធូរបន្ថយសម្រាប់អ្នកទទួលរងនោះ

لِأَنَّهُ لَا يَكُوْنُ إِلَّا عَنْ غَضَبِكَ وَانْتِقَامِكَ وَ سَخَطِكَ، وَ هَذَا مَا لَا تَقُوْمُ لَهُ السَّمَاوَاتُ وَالْأَرْضُ،

ព្រោះវាកើតមានឡើងមកពីព្រះពិរោធរបស់ព្រះអង្គ មកពីការសងសឹករបស់ព្រះអង្គ និងមកពីព្រះទោសៈរបស់ព្រះអង្គ ។ ទាំងនេះ បណ្តាមេឃ ផែនដីក៏ពុំអាចស៊ូទ្រាំបានឡើយដែរ !

يَا سَيِّدِيْ فَكَيْفَ بِيْ وَ أَنَا عَبْدُكَ الضَّعِيْفُ الذَّلِيْلُ، الْحَقِيْرُ الْمِسْكِيْنُ

ឱព្រះអភិបាលទូលព្រះបង្គំជាខ្ញុំអឺយ ទូលព្រះបង្គំជាខ្ញុំនឹងអាចស៊ូទ្រាំបានដូចម្តេចទៅព្រោះទូលព្រះបង្គំជាខ្ញុំជាបាវទន់ខ្សោយរបស់ព្រះអង្គ ដែលថោកទាប ដែលគម្រាំង ដែលតោកយ៉ាក ដែលទ័លក្រដុនដាប ?

يَا إِلَهِي وَ رَبِّيْ وَ سَيِّدِيْ وَ مَوْلَايَ، لِأَيِّ الْأُمُوْرِ إِلَيْكَ أَشْكُوْ، وَ لِمَا مِنْهَا أَضِجُّ وَ أَبْكِيْ،

ឱព្រះទូលព្រះបង្គំជាខ្ញុំអើយ ឱព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំអើយ ឱព្រះអភិបាលទូលព្រះបង្គំជាខ្ញុំអើយ ឱព្រះអគ្គប្រមុខទូលព្រះបង្គំជាខ្ញុំអើយ តើនឹងឲ្យទូលព្រះបង្គំជាខ្ញុំសាទុក្ខមួយណាប្រាប់ព្រះអង្គ ក្នុងចំណោមទុក្ខវេនាទាំងឡាយ តើនឹងឲ្យទូលព្រះបង្គំជាខ្ញុំយំយែកប្រាប់ព្រះអង្គអំពីទុក្ខមួយណា ក្នុងចំណោមទុក្ខវេទនាទាំងនោះ ?

لِأَلِيْمِ الْعَذَابِ وَشِدَّتِهِ أَمْ لِطُوْلِ الْبَلَآءِ وَمُدَّتِهِ،

[នឹងយំស្រែក] អំពីការឈឺចាប់និងភាពតឹងរ៉ឹងនៃទណ្ឌកម្ម ឬអំពីនិច្ចភាពនិងអំឡុងពេលដ៏យូរនៃទុក្ខវេទនា ?

فَلَئِنْ صَيَّرْتَنِيْ لِلْعُقُوْبَاتِ مَعَ أَعْدَائِكَ ، وَ جَمَعْتَ بَيْنِيْ وَ بَيْنَ أَهْلِ بَلَآئِكَ،

បើសិនជាព្រះអង្គដាក់ទណ្ឌកម្មទូលព្រះបង្គំជាខ្ញុំ ជាមួយសត្រូវរបស់ព្រះអង្គ [បើសិនជា]ព្រះអង្គដាក់ទូលព្រះបង្គំជាខ្ញុំ ជាមួយពួកដែលព្រះអង្គដាក់ឲ្យទទួលរងទុក្ខវេទនា

وَ فَرَّقْتَ بَيْنِيْ وَ بَيْنَ أَحِبَّائِكَ وَ أَوْلِيَائِكَ ،

[បើសិនជា]ព្រះអង្គបំបែកទូលព្រះបង្គំជាខ្ញុំចេញពីបណ្ដាកល្យាណមិត្ត និងបណ្ដាសន្តបុគ្គលរបស់ព្រះអង្គ

فَهَبْنِيْ يَا إِلَهِي وَ سَيِّدِيْ وَ مَوْلَايَ وَرَبِّيْ صَبَرْتُ عَلَى عَذَابِكَ، فَكَيْفَ أَصْبِرُ عَلَى فِرَاقِكَ،

ឱព្រះទូលព្រះបង្គំជាខ្ញុំអើយ ឱព្រះអភិបាលទូលព្រះបង្គំជាខ្ញុំអើយ ឱព្រះអគ្គប្រមុខទូលព្រះបង្គំជាខ្ញុំអើយ ឱព្រះជាម្ចាស់ទូលព្រះបង្គំជាខ្ញុំអើយ ឧបមាថាទូលព្រះបង្គំជាខ្ញុំអាចស៊ូទ្រាំទណ្ឌកម្មរបស់ព្រះអង្គបាន តើទូលព្រះបង្គំជាខ្ញុំនឹងអាចអត់ទ្រាំការ

ប្រាសព្រាត់ពីព្រះអង្គបានដូចម្ដេចទៅ ?

وَ هَبْنِيْ صَبَرْتُ عَلَى حَرِّ نَارِكَ، فَكَيْفَ أَصْبِرُ عَنِ النَّظَرِ إِلَى كَرَامَتِكَ، أَمْ كَيْفَ أَسْكُنُ فِيْ النَّارِ وَ رَجَائِيْ عَفْوُكَ،

ឧបមាថាទូលព្រះបង្គំជាខ្ញុំអត់ទ្រាំកម្ដៅភ្លើងរនករបស់ព្រះអង្គបាន តើទូលព្រះបង្គំជាខ្ញុំនឹងអាចអត់ទ្រាំ ការមិនបានឃើញព្រះហឫទ័យទូលាយរបស់ព្រះអង្គបានដូចម្ដេចទៅ ? តើទូលព្រះបង្គំជាខ្ញុំនឹងអាចរស់នៅក្នុងភ្លើងនរកបានម្ដេចទៅបើចិត្តទូលព្រះបង្គំជាខ្ញុំសង្ឃឹមតែទទួលបាននូវការអភ័យទោសពីព្រះអង្គនោះ ?

فَبِعِزَّتِكَ يَا سَيِّدِيْ وَ مَوْلَايَ أُقْسِمُ صَادِقًا، لَئِنْ تَرَكْتَنِيْ نَاطِقًا لَأَضِجَّنَّ إِلَيْكَ بَيْنَ أَهْلِهَا ضَجِيْجَ الْآمِلِيْنَ،

ហេតុដូច្នេះ ឱព្រះអភិបាលទូលព្រះបង្គំជាខ្ញុំអើយ ឱព្រះអគ្គប្រមុខព្រះបង្គំជាខ្ញុំអើយ ដោយនូវព្រះមហិទ្ធិឫទ្ធិរបស់ព្រះអង្គ ទូលព្រះបង្គំជាខ្ញុំសូមស្បថដោយស្មោះអស់ពីចិត្ត ក្នុងព្រះនាមព្រះអាជ្ញាធរព្រះអង្គ ថាបើព្រះអង្គឲ្យទូលព្រះបង្គំជាខ្ញុំអាចនិយាយបាន ពិតណាស់ ទូលព្រះបង្គំជាខ្ញុំនឹងស្រែករកព្រះអង្គ ក្នុងចំណោមប្រជានិកររបស់វា (គឺក្នុងភ្លើងនរក) ឲ្យឮសូរកងរំពងដូចសូរកងរំពងរបស់បណ្ដាអ្នកមានសង្ឃឹមដែរ

وَ لَأَصْرُخَنَّ إِلَيكَ صُرَاخَ الْمُسْتَصْرِخِينَ، وَ لَأَبْكِيَنَّ عَلَيْكَ بُكَاءَ الْفَاقِدِيْنَ، وَ لَأُنَادِيَنَّكَ أَيْنَ كُنْتَ

ទូលព្រះបង្គំជាខ្ញុំនឹងស្រែកដូចបណ្ដាអ្នកស្រែករកជំនួយ ទូលព្រះបង្គំជាខ្ញុំនឹងយំយែករកព្រះអង្គដូចបណ្ដាអ្នកដែលយំយែកលើអ្នកស្លាប់របស់ពួកគេ ហើយទូលព្រះបង្គំជាខ្ញុំនឹងស្រែករកព្រះអង្គថា៖ "ព្រះអង្គនៅឯណា ?"

يَا وَلِيَّ الْمُؤْمِنِيْنَ، يَا غَايَةَ آمَالِ الْعَارِفِيْنَ، يَا غِيَاثَ الْمُسْتَغِيْثِيْنَ، يَا حَبِيْبَ قُلُوْبِ الصَّادِقِيْنَ،

وَيَا إِلٰهَ الْعَالَمِيْنَ،
ឱព្រះរាជអគ្គប្រមុខរបស់បណ្តាអ្នកមានសទ្ធាជ្រះថ្លាអឺយ ឱព្រះគោលដៅនៃសេចក្តីសង្ឃឹមរបស់បណ្តាអ្នកដឹងអឺយ ឱព្រះរាជជំនួយរបស់បណ្តាអ្នកស្រែករកជំនួយអឺយ ឱជាទីស្រឡាញ់របស់បណ្តាដួងចិត្តនៃបណ្តាសច្ចការីអឺយ ឱព្រះនៃពិភពទាំងពួងអឺយ

أَفَتُرَاكَ سُبْحَانَكَ يَا إِلٰهِي وَبِحَمْدِكَ، تَسْمَعُ فِيْهَا صَوْتَ عَبْدٍ مُسْلِمٍ سُجِنَ فِيْهَا بِمُخَالَفَتِهِ،
សូមថ្វាយសេចក្តីរុងរឿងនិងសេចក្តីសរសើរចំពោះព្រះអង្គ ឱព្រះទូលព្រះបង្គំជាខ្ញុំអឺយ តើព្រះអង្គទ្រង់ព្រះសណ្តាប់សម្លេងបាវមានជំនឿម្នាក់ទេដែលជាប់ឃុំនៅទីនោះ (ក្នុងនរក) ព្រោះតែប្រព្រឹត្តខុស ?

وَذَاقَ طَعْمَ عَذَابِهَا بِمَعْصِيَتِهِ، وَحُبِسَ بَيْنَ أَطْبَاقِهَا بِجُرْمِهِ وَجَرِيْرَتِهِ،
ដែលទទួលរងទារុណកម្មដោយសារតែគេបានប្រព្រឹត្តល្មើស ដែលត្រូវឃុំឃាំងនៅឯជាន់[នរក] ដោយសារតែបទឧក្រិដ្ឋនិងបាបកម្មរបស់គេ

وَهُوَ يَضِجُّ إِلَيْكَ ضَجِيْجَ مُؤَمِّلٍ لِرَحْمَتِكَ، وَيُنَادِيْكَ بِلِسَانِ أَهْلِ تَوْحِيْدِكَ، وَيَتَوَسَّلُ إِلَيْكَ بِرُبُوْبِيَّتِكَ، يَا مَوْلَايَ
ដែលស្រែករកព្រះអង្គ ដោយសម្រែករបស់អ្នកដែលសង្ឃឹមនឹងបានទទួលព្រះមេត្តាប្រណីពីព្រះអង្គ ដែលស្រែកហៅព្រះអង្គដោយសម្តីរបស់បណ្តាអ្នកតៅហ៊ីដ្ (គឺមានជំនឿលើព្រះអង្គតែមួយគត់) ដែលអង្វរករព្រះអង្គក្នុងព្រះនាមព្រះគុណានៃព្រះអភិបាលភាពព្រះអង្គ ឱព្រះអគ្គប្រមុខទូលព្រះបង្គំជាខ្ញុំអឺយ ?

فَكَيْفَ يَبْقَى فِي الْعَذَابِ وَهُوَ يَرْجُوْ مَا سَلَفَ مِنْ حِلْمِكَ،
នឹងបណ្តោយឲ្យនៅក្នុងទណ្ឌកម្ម អ្នកដែលសង្ឃឹមនឹងបានទទួលនូវសេចក្តីប្រោសប្រណីពីព្រះអង្គកាលពីមុនមកម្ល៉េះនោះ ?

أَمْ كَيْفَ تُؤْلِمُهُ النَّارُ وَهُوَ يَأْمُلُ فَضْلَكَ وَرَحْمَتَكَ ،
នឹងបណ្ដោយឲ្យភ្លើងដុតរោលគេឬ ថ្វីបើគេសង្ឃឹមនឹងបានទទួលព្រះធម៌មេត្តានិងព្រះករុណាមេត្តារបស់ព្រះអង្គ ?

أَمْ كَيْفَ يُحْرِقُهُ لَهِيبُهَا وَأَنْتَ تَسْمَعُ صَوْتَهُ وَتَرَى مَكَانَهُ ،
តើនឹងបណ្ដោយឲ្យភ្លើង(នរក)ដុតរោលគេឬ ថ្វីបើព្រះអង្គឮសម្លេងគេ ព្រះអង្គឃើញគេនៅទីនោះ ?

أَمْ كَيْفَ يَشْتَمِلُ عَلَيْهِ زَفِيرُهَا وَأَنْتَ تَعْلَمُ ضَعْفَهُ ،
តើនឹងបណ្ដោយឲ្យគេនៅក្នុងកម្ដៅភ្លើង(នរក)ឬ ថ្វីបើព្រះអង្គទ្រង់ញាណនូវភាពទន់ខ្សោយរបស់គេ ?

أَمْ كَيْفَ يَتَقَلْقَلُ بَيْنَ أَطْبَاقِهَا وَأَنْتَ تَعْلَمُ صِدْقَهُ ،
តើនឹងបណ្ដោយឲ្យគេរមូលខ្លួននៅរវាងជាន់(នរក)ឬ ថ្វីបើព្រះអង្គទ្រង់ញាណនូវសេចក្ដីស្មោះត្រង់របស់គេ ?

أَمْ كَيْفَ تَزْجُرُهُ زَبَانِيَتُهَا وَهُوَ يُنَادِيكَ يَا رَبَّهُ ،
តើនឹងបណ្ដោយឲ្យបណ្ដាភ្នាក់ងារ (គឺពួកទេវតាធ្វើទោស) ធ្វើទោសគេឬ ថ្វីបើគេហៅព្រះអង្គថា៖ "ឱព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំអើយ !" ?

أَمْ كَيْفَ يَرْجُو فَضْلَكَ فِي عِتْقِهِ مِنْهَا فَتَتْرُكَهُ فِيهَا ،
តើព្រះអង្គនឹងបណ្ដោយឲ្យគេនៅទីនោះឬ ថ្វីបើគេសង្ឃឹមនឹងបានទទួលព្រះមេត្តានៃព្រះអង្គដើម្បីនឹងបានរួចផុតពីទីនោះ ?

هَيْهَاتَ مَا ذَلِكَ الظَّنُّ بِكَ وَلاَ الْمَعْرُوفُ مِنْ فَضْلِكَ ، وَلاَ مُشْبِهٌ لِمَا عَامَلْتَ بِهِ الْمُوَحِّدِيْنَ مِنْ بِرِّكَ وَإِحْسَانِكَ ،

ទេ ! គេមិនជឿថាព្រះអង្គដូច្នេះទេ ! ពីព្រោះតាមដែលគេបានដឹងបានយល់អំពីព្រះអនុគ្រោះរបស់ព្រះអង្គ អំពីព្រះហឫទ័យមេត្តារបស់ព្រះអង្គនិងព្រះគុណូបការៈរបស់ព្រះអង្គ ដែលព្រះអង្គមានលើបណ្ដាអ្នកមានភក្ដីភាពចំពោះព្រះអង្គតែមួយគត់នោះ ពុំអាចឲ្យគេជឿបានថាព្រះអង្គ (មានព្រះហឫទ័យឃោរឃៅ) ដូច្នោះជាដាច់ខាត !

فَبِالْيَقِيْنِ أَقْطَعُ ، لَوْ لاَ مَا حَكَمْتَ بِهِ مِنْ تَعْذِيْبِ جَاحِدِيْكَ ، وَقَضَيْتَ بِهِ مِنْ إِخْلاَدِ مُعَانِدِيْكَ ،

ទូលព្រះបង្គំជាខ្ញុំអះអាងដោយជឿជាក់ថា បើសិនជាព្រះអង្គពុំបានដាក់ទោសលើបណ្ដាជនបះបោរ និងពុំបានដាក់ព្រះបញ្ជាឲ្យពួកប្រព្រឹត្តិល្មើសចំពោះព្រះអង្គទទួលរងនរកជានិច្ចនិរន្តរទេនោះ

لَجَعَلْتَ النَّارَ كُلَّهَا بَرْدًا وَسَلاَمًا ، وَمَا كَانَتْ لِأَحَدٍ فِيْهَا مَقَرًّا وَلاَ مُقَامًا

ព្រះអង្គនឹងធ្វើឲ្យភ្លើង (នរក) ត្រជាក់និងស្ងប់ស្ងាត់ ហើយគេនឹងពុំឃើញមានទីអាស្រ័យនិងជម្រកឡើយ ។

لَكِنَّكَ تَقَدَّسَتْ أَسْمَاؤُكَ أَقْسَمْتَ أَنْ تَمْلَأَهَا مِنَ الْكَافِرِيْنَ ، مِنَ الْجِنَّةِ وَالنَّاسِ أَجْمَعِيْنَ ، وَأَنْ تُخَلِّدَ فِيْهَا الْمُعَانِدِيْنَ ،

តែព្រះអង្គ ឱព្រះដ៏មានព្រះបូជនីយនាម បានស្បថថាព្រះអង្គនឹងដាក់ពួកអសទ្ធាក្នុងចំណោមពួកយិននិងពួកមនុស្ស និងពួកចចេសប្រព្រឹត្តល្មើស ឲ្យនៅពេញទីនោះជានិច្ចអនន្ត ។

وَأَنْتَ جَلَّ ثَنَاؤُكَ قُلْتَ مُبْتَدِئًا ، وَتَطَوَّلْتَ بِالْإِنْعَامِ مُتَكَرِّمًا ،

ហើយព្រះអង្គ ឱព្រះដ៏ប្រកបដោយសេចក្ដីសរសើររុងរឿងឥតរៀបរាប់បាន មាន

ព្រះបន្ទូលកាលពីមុនមកហើយ ដោយមានព្រះបំណងលាតសន្ធឹងព្រះហឫទ័យទូលំទូលាយរបស់ព្រះអង្គ ថា៖

{أَفَمَنْ كَانَ مُؤْمِنًا كَمَنْ كَانَ فَاسِقًا لَا يَسْتَوُونَ}.
"តើជនមានសទ្ធាដូចគ្នានឹងជនកំណាចទេ? ពួកគេមិនដូចគ្នាទេ! (ស៊ូ.៣២, អា.១៨)

إِلَهِي وَ سَيِّدِيْ، فَأَسْأَلُكَ بِالْقُدْرَةِ الَّتِيْ قَدَّرْتَهَا، وَبِالْقَضِيَّةِ الَّتِيْ حَتَمْتَهَا وَ حَكَمْتَهَا، وَ غَلَبْتَ مَنْ عَلَيْهِ أَجْرَيْتَهَا،
ឱព្រះទូលព្រះបង្គំជាខ្ញុំអើយ ឱព្រះអភិបាលទូលព្រះបង្គំជាខ្ញុំអើយ ទូលព្រះបង្គំជាខ្ញុំសូមអង្វរព្រះអង្គ ក្នុងព្រះនាមនៃព្រះមហិទ្ធិឫទ្ធិដែលព្រះអង្គមាន ក្នុងព្រះនាមនៃព្រះវិនិច្ឆ័យដែលព្រះអង្គបានដាក់មកនិងបានសម្រេច ហើយព្រះអង្គបានយកជ័យជំនះលើបុគ្គលដែលព្រះអង្គបានដាក់ព្រះវិនិច្ឆ័យនេះមកឲ្យអនុវត្តិនោះ

أَنْ تَهَبَ لِيْ، فِيْ هَذِهِ اللَّيْلَةِ، وَ فِيْ هَذِهِ السَّاعَةِ، كُلَّ جُرْمٍ أَجْرَمْتُهُ، وَ كُلَّ ذَنْبٍ أَذْنَبْتُهُ، وَ كُلَّ قَبِيْحٍ أَسْرَرْتُهُ،

សូមទ្រង់ព្រះមេត្តាលើកលែងឲ្យទូលព្រះបង្គំជាខ្ញុំ នាយប់នេះ នាម៉ោងនេះ ដែលបានប្រព្រឹត្តបណ្តាបទឧក្រិដ្ឋ ដែលបានសាងបាប ដែលបានបិទបាំងគ្រប់អំពើគួរស្អប់ខ្ពើម

وَكُلَّ جَهْلٍ عَمِلْتُهُ، كَتَمْتُهُ أَوْ أَعْلَنْتُهُ، أَخْفَيْتُهُ أَوْ أَظْهَرْتُهُ،
ដែលបានប្រព្រឹត្តគ្រប់អំពើដោយអចេតនា ដោយលាក់បាំងឬដោយបើកឲ្យឃើញ

وَكُلَّ سَيِّئَةٍ أَمَرْتَ بِإِثْبَاتِهَا الْكِرَامَ الْكَاتِبِيْنَ،

ដែលបានប្រព្រឹត្តគ្រប់អំពើអាក្រក់ ដែលព្រះអង្គបានឲ្យបណ្តាទេវតាកត់ហេតុការណ៍ជាសាក្សី

الَّذِيْنَ وَكَّلْتَهُمْ بِحِفْظِ مَا يَكُوْنُ مِنِّيْ، وَ جَعَلْتَهُمْ شُهُوْدًا عَلَيَّ مَعَ جَوَارِحِيْ،

ដែលព្រះអង្គបានឲ្យកត់ត្រាទុកនូវអ្វីទាំងអស់ ដែលចេញមកពីទូលព្រះបង្គំជាខ្ញុំ និងដែលព្រះអង្គបានដាក់មកជាសាក្សីគួបនឹងអវយវៈទូលព្រះបង្គំជាខ្ញុំដែរ ដើម្បីជំទាស់ទូលព្រះបង្គំជាខ្ញុំ

وَ كُنْتَ أَنْتَ الرَّقِيْبَ عَلَيَّ مِنْ وَرَائِهِمْ، وَالشَّاهِدَ لِمَا خَفِيَ عَنْهُمْ، وَبِرَحْمَتِكَ أَخْفَيْتَهُ، وَ بِفَضْلِكَ سَتَرْتَهُ،

ព្រះអង្គឃ្លាំទតទូលព្រះបង្គំជាខ្ញុំ នៅពីក្រោយពួកគេ (គឺបណ្តាទេវតាអ្នកកត់ត្រា និងអវយវៈ) ហើយព្រះអង្គជាសាក្សីនៃអ្វីដែលអាចរបូតរួចពីពួកគេដែលទូលព្រះបង្គំជាខ្ញុំអាចលាក់ទុកបានអាស្រ័យព្រះមេត្តាធម៌ព្រះអង្គ ដែលទូលព្រះបង្គំជាខ្ញុំអាចបិទបាំងបានអាស្រ័យសេចក្តីប្រោសប្រណីរបស់ព្រះអង្គ

وَ أَنْ تُوَفِّرَ حَظِّيْ مِنْ كُلِّ خَيْرٍ تُنْزِلُهُ أَوْ إِحْسَانٍ تُفْضِلُهُ

[ទូលព្រះបង្គំជាខ្ញុំ] សូមទ្រង់ព្រះមេត្តាព្រះរាជទានឲ្យទូលព្រះបង្គំជាខ្ញុំមួយចំណែកធំក្នុងចំណោមសេចក្តីល្អដែលព្រះអង្គបានប្រទានមក ក្នុងចំណោមអ្វីៗដែលល្អប្រសើរដែលព្រះអង្គដាក់មកជាចំណោយ

أَوْ بِرٍّ تَنْشُرُهُ، أَوْ رِزْقٍ تَبْسُطُهُ، أَوْ ذَنْبٍ تَغْفِرُهُ، أَوْ خَطَإٍ تَسْتُرُهُ

ក្នុងចំណោមព្រះសប្បុរសធម៌ដែលព្រះអង្គប្រោះមក ក្នុងចំណោមគុណប្រយោជន៍ដែលព្រះអង្គចែកមក ក្នុងចំណោមការលុបលាងបណ្តាបាបដែលព្រះអង្គព្រះរាជទានមក ឬក្នុងចំណោមកំហុសទាំងអស់ដែលព្រះអង្គបិទបាំងឲ្យ

يَا رَبِّ يَا رَبِّ يَا رَبِّ، يَا إِلٰهِي وَسَيِّدِيْ وَمَوْلَايَ وَمَالِكَ رِقِّيْ،
ឱព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំអឺយ ឱព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំអឺយ ឱព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំអឺយ ឱព្រះទូលព្រះបង្គំជាខ្ញុំអឺយ ឱព្រះអភិបាលទូលព្រះបង្គំជាខ្ញុំអឺយ ឱព្រះអគ្គប្រមុខទូលព្រះបង្គំជាខ្ញុំអឺយ ឱព្រះម្ចាស់ច្រវ៉ាក់ទូលព្រះបង្គំជាខ្ញុំអឺយ

يَا مَنْ بِيَدِهِ نَاصِيَتِيْ، يَا عَلِيْمًا بِضُرِّيْ وَمَسْكَنَتِيْ، يَا خَبِيْرًا بِفَقْرِيْ وَفَاقَتِيْ، يَا رَبِّ يَا رَبِّ يَا رَبِّ،
ឱព្រះអ្នកក្តាប់ជោគវាសនាទូលព្រះបង្គំជាខ្ញុំក្នុងព្រះហត្ថ ឱព្រះទ្រង់ញាណទុក្ខវេទនានិងភាពទ័លក្ររបស់ទូលព្រះបង្គំជាខ្ញុំ ឱព្រះទ្រង់ញាណការខ្វះខាតនិងក្តីក្រខ្សត់របស់ទូលព្រះបង្គំជាខ្ញុំ ឱព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំអឺយ ឱព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំអឺយ ឱព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំអឺយ

أَسْأَلُكَ بِحَقِّكَ وَقُدْسِكَ وَأَعْظَمِ صِفَاتِكَ وَأَسْمَائِكَ،
ទូលព្រះបង្គំជាខ្ញុំសូម ក្នុងព្រះនាមនៃព្រះយុត្តិធម៌និងព្រះបូជនីយភាពនៃព្រះអង្គ ក្នុងព្រះនាមនៃព្រះគុណសម្បត្តិនិងព្រះរាជនាមដ៏រុងរឿងលើសលុបនៃព្រះអង្គ

أَنْ تَجْعَلَ أَوْقَاتِيْ فِيْ اللَّيْلِ وَالنَّهَارِ بِذِكْرِكَ مَعْمُوْرَةً، وَبِخِدْمَتِكَ مَوْصُوْلَةً،
ព្រះមេត្តាឲ្យទូលព្រះបង្គំជាខ្ញុំបានបួងសួងព្រះអង្គទាំងថ្ងៃយប់ និងបម្រើព្រះអង្គជានិច្ចឥតដាច់

وَأَعْمَالِيْ عِنْدَكَ مَقْبُوْلَةً، حَتّٰى تَكُوْنَ أَعْمَالِيْ وَأَوْرَادِيْ كُلُّهَا وِرْدًا وَاحِدًا، وَحَالِيْ فِيْ خِدْمَتِكَ سَرْمَدًا،
សូមឲ្យទង្វើទាំងឡាយរបស់ទូលព្រះបង្គំជាខ្ញុំសព្វព្រះហឫទ័យព្រះអង្គ ដើម្បីនឹងឲ្យគ្រប់អំពើនិងគ្រប់ការបួងសួងរបស់ទូលព្រះបង្គំជាខ្ញុំ ទៅជាការអង្វរបួងសួងតែ

មួយ និងដើម្បីនឹងឲ្យទូលព្រះបង្គំជាខ្ញុំបាននៅបម្រើព្រះអង្គជានិច្ចនិរន្តរ

يَا سَيِّدِيْ يَا مَنْ عَلَيْهِ مُعَوَّلِيْ، يَا مَنْ إِلَيْهِ شَكَوْتُ أَحْوَالِيْ، يَا رَبِّ يَا رَبِّ يَا رَبِّ،
ព្រះអភិបាលទូលព្រះបង្គំជាខ្ញុំអឺយ ព្រះជាទីពឹងពាក់របស់ទូលព្រះបង្គំជាខ្ញុំអឺយ ព្រះដែលទូលព្រះបង្គំជាខ្ញុំត្អូញត្អែរប្រាប់នូវស្ថានភាពទូលព្រះបង្គំជាខ្ញុំអឺយ ព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំអឺយ ឱព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំអឺយ ព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំអឺយ

قَوِّ عَلَى خِدْمَتِكَ جَوَارِحِيْ، وَاشْدُدْ عَلَى الْعَزِيْمَةِ جَوَانِحِيْ،
សូមទ្រង់ព្រះមេត្តាពង្រឹងអវយវៈទូលព្រះបង្គំជាខ្ញុំ ដើម្បីនឹងឲ្យវាបាននៅបម្រើព្រះអង្គ សូមទ្រង់ព្រះមេត្តាពង្រឹងខ្នងទូលព្រះបង្គំជាខ្ញុំដោយសេចក្តីប្តេជ្ញាចិត្តមោះមុត [ដើម្បីនៅបម្រើព្រះអង្គ]

وَهَبْ لِيَ الْجِدَّ فِيْ خَشْيَتِكَ، وَالدَّوَامَ فِيْ الْإِتِّصَالِ بِخِدْمَتِكَ،
សូមទ្រង់ព្រះមេត្តាឲ្យទូលព្រះបង្គំជាខ្ញុំខ្លាចព្រះអង្គដោយស្មោះអស់ពីចិត្ត និងឲ្យទូលព្រះបង្គំជាខ្ញុំបាននៅបម្រើព្រះអង្គជានិច្ចនិរន្តរឥតដាច់ឡើយ

حَتَّى أَسْرَحَ إِلَيْكَ فِيْ مَيَادِيْنِ السَّابِقِيْنَ، وَأُسْرِعَ إِلَيْكَ فِيْ الْمُبَادِرِيْنَ
ដើម្បីទូលព្រះបង្គំជាខ្ញុំឆ្ពោះទៅរកព្រះអង្គបានយ៉ាងងាយស្រួល ក្នុងចំណោមជនដែលប្រកួតគ្នាឆ្ពោះទៅរកព្រះអង្គ ឲ្យទូលព្រះបង្គំជាខ្ញុំជាបុគ្គលមុខគេក្នុងចំណោមជនដែលប្រញាប់ប្រញាល់ដើម្បីបានចូលទៅក្បែរព្រះអង្គ

وَاشْتَاقَ إِلَى قُرْبِكَ فِيْ الْمُشْتَاقِيْنَ، وَأَدْنُوَ مِنْكَ دُنُوَّ الْمُخْلِصِيْنَ،
[ឲ្យទូលព្រះបង្គំជាខ្ញុំជាបុគ្គលមុខគេ]ដែលចង់បាននៅជិតព្រះអង្គយ៉ាងខ្លាំង ក្នុងចំណោមអ្នកចង់បានខ្លាំង ដែលខឹតចូលទៅជិតព្រះអង្គដែលប្រកបដោយការខិតចូលជិតរបស់បណ្តាអ្នកស្មោះត្រង់

وَأَخَافَكَ مَخَافَةَ الْمُوْقِنِيْنَ، وَأَجْتَمِعَ فِيْ جِوَارِكَ مَعَ الْمُؤْمِنِيْنَ.

[ដើម្បីទូលព្រះបង្គំជាខ្ញុំនឹង] ខ្លាចព្រះអង្គដូចបណ្តាអ្នកខ្លាចព្រះអង្គដោយជឿជាក់ពិតប្រាកដ [ដើម្បីទូលព្រះបង្គំជាខ្ញុំនឹង] បាននៅជាមួយបណ្តាអ្នកមានសទ្ធាស៊ប់ចិត្តដែលនៅក្បែរព្រះអង្គ ។

اللَّهُمَّ وَمَنْ أَرَادَنِيْ بِسُوْءٍ فَأَرِدْهُ، وَمَنْ كَادَنِيْ فَكِدْهُ،

ឱព្រះទូលព្រះបង្គំជាខ្ញុំអើយ បុគ្គលណាដែលប្រាថ្នាអាក្រក់លើទូលព្រះបង្គំជាខ្ញុំ សូមទ្រង់ព្រះមេត្តាប្រាថ្នាអាក្រក់សងបុគ្គលនោះវិញ បុគ្គលណាដែលបៀតបៀនទូលព្រះបង្គំជាខ្ញុំ សូមទ្រង់ព្រះមេត្តាបៀតបៀនបុគ្គលនោះ

وَاجْعَلْنِيْ مِنْ أَحْسَنِ عَبِيْدِكَ نَصِيْبًا عِنْدَكَ، وَأَقْرَبِهِمْ مَنْزِلَةً مِنْكَ، وَأَخَصِّهِمْ زُلْفَةً لَدَيْكَ،

សូមទ្រង់ព្រះមេត្តាព្រះរាជទានឲ្យទូលព្រះបង្គំជាខ្ញុំនូវចំណែកមួយពីព្រះអង្គ ដែលប្រសើរបំផុតក្នុងចំណោមបាវទាំងឡាយរបស់ព្រះអង្គ ឲ្យទូលព្រះបង្គំជាខ្ញុំបាននូវលំដាប់ថ្នាក់ជិតព្រះអង្គជាងគេ និងជាជំនិតព្រះអង្គដែលស្មោះស្ម័គ្រជាងគេ

فَإِنَّهُ لَا يُنَالُ ذَلِكَ إِلَّا بِفَضْلِكَ،

ព្រោះអ្វីទាំងនេះនឹងបានមកដោយសារតែព្រះអង្គទ្រង់ព្រះមេត្តាប្រោសប្រណី !

وَجُدْ لِيْ بِجُوْدِكَ، وَاعْطِفْ عَلَيَّ بِمَجْدِكَ، وَاحْفَظْنِيْ بِرَحْمَتِكَ،

សូមទ្រង់ព្រះមេត្តាមានព្រះហឫទ័យទូលាយចំពោះទូលព្រះបង្គំជាខ្ញុំ សូមទ្រង់ព្រះមេត្តាអាសូរទូលព្រះបង្គំជាខ្ញុំ ក្នុងព្រះនាមនៃព្រះវិរោចនភាពនៃព្រះអង្គ សូមទ្រង់ព្រះមេត្តាការពារទូលព្រះបង្គំជាខ្ញុំ ក្នុងព្រះនាមនៃព្រះមេត្តាករុណានៃព្រះអង្គ

وَاجْعَلْ لِسَانِيْ بِذِكْرِكَ لَهِجًا، وَقَلْبِيْ بِحُبِّكَ مُتَيَّمًا،

សូមទ្រង់ព្រះមេត្តាឲ្យអណ្តាតទូលព្រះបង្គំជាខ្ញុំបានបួងសួងព្រះអង្គឥតដាច់ ឲ្យដួងចិត្តទូលព្រះបង្គំជាខ្ញុំស្រឡាញ់ព្រះអង្គយ៉ាងខ្លាំង

وَمُنَّ عَلَيَّ بِحُسْنِ إِجَابَتِكَ، وَأَقِلْنِيْ عَثْرَتِيْ وَاغْفِرْ زَلَّتِيْ،

សូមទ្រង់ព្រះមេត្តាឆ្លើយតបសំណូមទូលព្រះបង្គំជាខ្ញុំ សម្រាលបណ្តាកំហុសទូលព្រះបង្គំជាខ្ញុំ និងអភ័យការភ្លាត់ភ្លាំងរបស់ទូលព្រះបង្គំជាខ្ញុំ

فَإِنَّكَ قَضَيْتَ عَلَى عِبَادِكَ بِعِبَادَتِكَ، وَأَمَرْتَهُمْ بِدُعَائِكَ، وَضَمِنْتَ لَهُمُ الْإِجَابَةَ،

ព្រោះព្រះអង្គបានដាក់ព្រះរាជបញ្ជាលើបណ្តាបាវព្រះអង្គ ឲ្យគោរពបូជាដ៏ខ្ពង់ខ្ពស់ចំពោះព្រះអង្គ ដាក់ព្រះរាជបញ្ជាឲ្យពួកគេបួងសួងព្រះអង្គ ហើយព្រះអង្គបានធានាពួកគេថាព្រះអង្គនឹងឆ្លើយតបពួកគេ !

فَإِلَيْكَ يَا رَبِّ نَصَبْتُ وَجْهِيْ، وَإِلَيْكَ يَا رَبِّ مَدَدْتُ يَدِيْ،

ដូច្នេះ ឱព្រះជាម្ចាស់ទូលព្រះបង្គំជាខ្ញុំអើយ ទូលព្រះបង្គំជាខ្ញុំបានបែរមុខទៅរកព្រះអង្គ ហើយទូលព្រះបង្គំជាខ្ញុំឈោងដៃទៅរកព្រះអង្គ ឱព្រះជាម្ចាស់ទូលព្រះបង្គំជាខ្ញុំអើយ ។

فَبِعِزَّتِكَ اسْتَجِبْ لِيْ دُعَائِيْ وَبَلِّغْنِيْ مُنَايَ، وَلَا تَقْطَعْ مِنْ فَضْلِكَ رَجَائِيْ، وَاكْفِنِيْ شَرَّ الْجِنِّ وَالْإِنْسِ مِنْ أَعْدَائِيْ،

ក្នុងព្រះនាមព្រះមហិទ្ធិឫទ្ធិព្រះអង្គ សូមទ្រង់ព្រះមេត្តាឆ្លើយតបទូលព្រះបង្គំជាខ្ញុំដោយយល់ព្រម សូមទ្រង់ព្រះមេត្តាឲ្យទូលព្រះបង្គំជាខ្ញុំសមបំណង សូមទ្រង់ព្រះមេត្តាកុំផ្តាច់សេចក្តីសង្ឃឹមរបស់ទូលព្រះបង្គំជាខ្ញុំលើព្រះមេត្តាប្រណីឡើយ សូមទ្រង់ព្រះមេត្តាឲ្យទូលព្រះបង្គំជាខ្ញុំគេចផុត ពីការព្យាបាទរបស់ពួកសត្រូវទូលព្រះបង្គំជាខ្ញុំ ទោះបីពួកវាជាយ៉ិនឬជាមនុស្សក៏ដោយ !

يَا سَرِيْعَ الرِّضَا، اغْفِرْ لِمَنْ لَا يَمْلِكُ إِلَّا الدُّعَاءَ، فَإِنَّكَ فَعَّالٌ لِمَا تَشَاءُ،
ឱព្រះអម្ចាស់ដ៏ពេញបំណងយ៉ាងឆាប់រហ័ស សូមទ្រង់ព្រះមេត្តាអភ័យទោសឲ្យបុគ្គលដែលមានតែការអង្វរបួងសួងមួយមុខ ព្រោះព្រះអង្គធ្វើអ្វីស្រេចតែព្រះអង្គប្រាថ្នា !

يَا مَنِ اسْمُهُ دَوَاءٌ، وَذِكْرُهُ شِفَاءٌ، وَطَاعَتُهُ غِنًى، إِرْحَمْ مَنْ رَأْسُ مَالِهِ الرَّجَاءُ، وَسِلَاحُهُ الْبُكَاءُ،
ឱព្រះដែលមានព្រះនាមជាឱសថ ដែលការបួងសួងព្រះអង្គធ្វើឲ្យជាសះស្បើយ ដែលការគោរពតាមព្រះអង្គជាទ្រព្យសម្បត្តិ សូមទ្រង់ព្រះមេត្តាអាណិតអាសូរបុគ្គលដែលមានតែសេចក្ដីសង្ឃឹមជាដើមទុន ដែលមានតែទឹកភ្នែកជាអាវុធ ។

يَا سَابِغَ النِّعَمِ، يَا دَافِعَ النِّقَمِ، يَا نُورَ الْمُسْتَوْحِشِيْنَ فِيْ الظُّلَمِ، يَا عَالِمًا لَا يُعَلَّمُ،
ឱព្រះអម្ចាស់ប្រទាននូវព្រះគុណូបការៈ ព្រះអម្ចាស់កម្ចាត់នូវអកុសល ឱព្រះដែលជាពន្លឺរបស់បណ្ដាអ្នកនៅឯកាក្នុងអន្ធការ ឱព្រះដែលទ្រង់ញាណដោយពុំមានរណាបង្ហាត់បង្រៀន

صَلِّ عَلَى مُحَمَّدٍ وَّآلِ مُحَمَّدٍ، وافْعَلْ بِيْ مَا أَنْتَ أَهْلُهُ،
សូមទ្រង់ព្រះមេត្តាព្រះរាជទានពរជ័យសិរីសួស្ដីដល់មូហ៊ាំម៉ាដ់ និងព្រះរាជកុលដ្ឋានរបស់មូហ៊ាំម៉ាដ់ផង ។ សូមទ្រង់ព្រះមេត្តាប្រព្រឹត្តចំពោះទូលព្រះបង្គំជាខ្ញុំអ្វីដែលស័ក្តិសមសម្រាប់ព្រះអង្គ !

وَصَلَّى اللّٰهُ عَلَى رَسُوْلِهِ وَالْأَئِمَّةِ الْمَيَامِيْنَ مِنْ آلِهِ وَسَلَّمَ تَسْلِيْمًا كَثِيْرًا.
សូមអល់ឡោះហ៏ព្រះរាជទានពរជ័យដល់ព្រះសាសនៈទូតរបស់ព្រះអង្គ និងដល់ព្រះសន្តអ៊ីមុាំទាំងឡាយនៃរាជព្រះរាជកុលដ្ឋានរបស់ព្រះអង្គ ។ សូមទ្រង់ព្រះរាជទានដល់សន្តបុគ្គលទាំងនេះនូវសិរីសួស្ដីដ៏ច្រើនមហិមាផង ។